[សម្រាប់ជនបរទេសធ្វើការនៅជប៉ុន]

カンボジア語版

# សៀវភៅណែនាំអំពីការស្នើសុំប្រាក់ធានារ៉ាប់រងគ្រោះថ្នាក់ការងារ

## <ភាគទី២>

## អំពីការឧបត្ថម្ភធានារ៉ាប់រងគ្រោះថ្នាក់ការងារ ខ្លឹមសារនៃធានារ៉ាប់រងគ្រោះថ្នាក់ការងារគ្រប់ប្រភេទ

ការធានារ៉ាប់រងគ្រោះថ្នាក់ការងារ ត្រូវបានគេអនុវត្តន៍ចំពោះគ្រប់ជនជាតិទាំងអស់ដែលធ្វើការនៅប្រទេសជប៉ុន។ ចំពោះអ្នកដែលមានវីសាការងារ គឺប្រាកដណាស់ ហើយអ្នកដែលជានិស្សិតដែលកំពុងសិក្សា ហើយមានគ្រោះថ្នាក់ពេលធ្វើការងារក្រៅម៉ោងក៏ដូចគ្នាដែរ។

សៀវភៅនេះធ្វើការពន្យល់អំពីប្រភេទនិងខ្លឹមសារនៃការ ឧបត្ថម្ភចំពោះធានារ៉ាប់រងគ្រោះថ្នាក់ការងាររបស់អ្នកធ្វើការជនជាតិបរទេស។

ចំពោះសេចក្តីលំអិតនៃលក្ខខណ្ឌនៃការផ្តល់ការឧបត្ថម្ភ សូមធ្វើការសាកសួរទៅការិយាល័យស្តង់ដារការងារ។ ហើយក៏មានការឧបត្ថម្ភខ្លះមិនអាចទទួលបានវិញដែរក្នុងករណីត្រឡប់ទៅប្រទេសវិញ សូមប្រុងប្រយ័ត្ន។

## 【មាតិកា】


អំពីការឧបត្ថម្ភធានារ៉ាប់រងគ្រោះថ្នាក់រងារ············P3
ក្នុងការឧបត្ថម្ភ(សំណង)ព្យាបាល····················P13
ប្រាក់ឧបត្ថម្ភ(សំណង)ឈប់សម្រាក សោធន៍និវត្តន៍(សំណង) របួសនិងជំងឺ ·································P15
ប្រាក់ឧបត្ថម្ភ(សំណង)ពិការភាព ····················P17
ប្រាក់ឧបត្ថម្ភ(សំណង)គ្រួសារ ប្រាក់ធ្វើបុណ្យសព·······P25
ប្រាក់ឧបត្ថម្ភ(សំណង)សម្រាប់ការថែទាំ···············P32
គំរូបំពេញ ································· P35


ផ្នែកសំណងនៃការិយាល័យស្តង់ដារការងារ
របស់ក្រសួងសង្គមកិច្ចនិងការងារ

# អ្វីជាធានារ៉ាប់រងគ្រោះថ្នាក់ការងារ

ធានារ៉ាប់រងគ្រោះថ្នាក់ការងារ ជាប្រព័ន្ធផ្តល់ការឧបត្ថម្ភធានារ៉ាប់រងសំរាប់ការព្យាបាល។ល។ នៅពេលដែលអ្នកធ្វើការមានរបួស មានជំងឺ ឬស្លាប់ដោយសារការធ្វើការឬធ្វើដំណើរទៅមកពីធ្វើការ។ ទោះជាជនបរទេសក៏ដោយ អោយតែធ្វើការនៅប្រទេសជប៉ុន គឺស្ថិតក្នុងក្របខ័ណ្ឌធានារ៉ាប់រងគ្រោះថ្នាក់ការងារនេះ។




※ចំពោះគ្រោះថ្នាក់ការងារ មិនអាចប្រើប្រាស់ធានារ៉ាប់រងសុខភាពបានទេ។

## ប្រភេទប្រាក់ឧបត្ថម្ភនៃធានារ៉ាប់រងគ្រោះថ្នាក់ការងារ

◆ការឧបត្ថម្ភ(សំណង)ព្យាបាល: ការឧបត្ថម្ភផ្តល់នៅពេលទទួលការព្យាបាលរបួសឬជំងឺដោយសារការធ្វើការឬធ្វើដំណើរទៅមកពីធ្វើការ

◆ប្រាក់ឧបត្ថម្ភ(សំណង)ឈប់សម្រាក: ប្រាក់ឧបត្ថម្ភផ្តល់នៅពេលទទួលការព្យាបាលរបួសឬជំងឺដោយសារការធ្វើការ ឬធ្វើដំណើរទៅមកពីធ្វើការ ហើយមិនអាចធ្វើការបាន និងមិនអាចទទួលកំរៃបាន

◆សោធន៍និវត្តន៍(សំណង)របួសនិងជំងឺ: ប្រាក់ឧបត្ថម្ភផ្តល់នៅពេលការព្យាបាលរបួសឬជំងឺដោយសារការធ្វើការ ឬធ្វើដំណើរទៅមកពីធ្វើការ ហើយក្រោយពីទទួលការព្យាបាល1ឆ្នាំ6ខែកន្លងទៅ របួសឬជំងឺមិននៅនឹង(អាការរោគលែងប្រែប្រួល) ហើយមានពិការភាពក្នុងកម្រិតស្របតាមកំរិតរបួសនិងជំងឺ

◆ប្រាក់ឧបត្ថម្ភ(សំណង)ពិការភាព: ប្រាក់ឧបត្ថម្ភផ្តល់នៅពេលការព្យាបាលរបួសឬជំងឺដោយសារការធ្វើការឬធ្វើដំណើរទៅមកពីធ្វើការ បាននៅនឹង(អាការរោគលែងប្រែប្រួល) ហើយនៅសល់ពិការភាពលើរាងកាយក្នុងកម្រិតពិការភាព

◆ប្រាក់ឧបត្ថម្ភ(សំណង)គ្រួសារ: ប្រាក់ឧបត្ថម្ភផ្តល់នៅពេលអ្នកធ្វើការបានបាត់បង់ជីវិត

◆ប្រាក់ធ្វើបុណ្យសព ប្រាក់ឧបត្ថម្ភសម្រាប់ធ្វើបុណ្យសព: ប្រាក់ឧបត្ថម្ភផ្តល់នៅពេលអ្នកធ្វើការបានបាត់បង់ជីវិត ហើយបានធ្វើពិធីបុណ្យសព

◆ប្រាក់ឧបត្ថម្ភ(សំណង)សម្រាប់ការថែទាំ: សំណងផ្តល់នៅពេលទទួលសោធន៍និវត្តន៍(សំណង)ពិការភាពឬសោធន៍និវត្តន៍(សំណង)របួសនិងជំងឺ ដែលមានពិការភាព ហើយកំពុងទទួលការថែទាំ

【និយមន័យពាក្យ①】

# គ្រោះថ្នាក់ពេលធ្វើការ

គ្រោះថ្នាក់ពេលធ្វើការ គឺគ្រោះថ្នាក់ដែលអ្នកធ្វើការ រងរបួសឬជំងឺ(របួស ជំងឺ ពិការភាព ស្លាប់) ដោយសារការធ្វើការងារ។

ការងារ ⟷ របួសឬជំងឺ។ល។

មានហេតុនិងផលទាក់ទងគ្នាមួយ

- ការដែលការងារនិងរបួសឬជំងឺមានហេតុនិងផលទាក់ទងគ្នាមួយហៅថា «ដោយសារការងារ»។
- ជាទូទៅ និយោជកនិងកម្មសិក្សាការីដែលមិនមែនជាអ្នកធ្វើការ មិនអាចទទួលសំណងបានទេ។

## ◇របួសដោយសារការងារគឺអ្វី

ចំពោះថាតើគ្រោះថ្នាក់ណា ដែលគេទទួលស្គាល់ថាជាគ្រោះថ្នាក់ពេលធ្វើការនោះ គេបែងចែកជា3ករណីដូចខាងក្រោម។

### <1>ក្នុងករណីធ្វើការងារនៅក្នុងកន្លែងរបស់ក្រុមហ៊ុន

ក្នុងករណីធ្វើការនៅក្នុងចន្លោះកំណត់នៃម៉ោងធ្វើការឬម៉ោងថែមនៅកន្លែង(ការិយាល័យ ឬ រោងចក្រ)របស់ក្រុមហ៊ុន បើគ្មានមូលហេតុពិសេស ត្រូវទទួលស្គាល់ថាជាគ្រោះថ្នាក់ពេលធ្វើការ។

※ក្នុងករណីដូចខាងក្រោមនេះ គេមិនទទួលស្គាល់ថាជាគ្រោះថ្នាក់ពេលធ្វើការទេ។

① ករណីដែលនៅពេលធ្វើការ អ្នកធ្វើការធ្វើសកម្មភាពឯកជន ហើយទទួលគ្រោះថ្នាក់
② ករណីអ្នកធ្វើការ បង្កគ្រោះថ្នាក់ដោយចេតនា
③ ករណីដែលអ្នកធ្វើការ រងការវាយតប់ពីជនទីៗ ដោយសារគំនុំផ្ទាល់ខ្លួន

**<2>ករណីមិនធ្វើការងារនៅក្នុងកន្លែងរបស់ក្រុមហ៊ុន**

គ្រោះថ្នាក់ដែលកើតឡើងដោយសារសកម្មភាពឯកជន នៅម៉ោងមិនទាន់ធ្វើការ ដូចជាម៉ោងសំរាកឬម៉ោងមុនឬក្រោយម៉ោងធ្វើការ មិនត្រូវបានទទួលស្គាល់ថាជាគ្រោះថ្នាក់ពេលធ្វើការទេ។ ប៉ុន្តែ បើសិនជាគ្រោះថ្នាក់កើតឡើងដោយសារសម្ភារៈ ឧបករណ៍របស់ក្រុមហ៊ុន ឬដោយសារការគ្រប់គ្រងនោះ គឺជាគ្រោះថ្នាក់ពេលធ្វើការ។ ម្យ៉ាងទៀតគ្រោះថ្នាក់ដែលកើតឡើងពេលធ្វើសកម្មភាពសរិរៈសាស្ត្រ ដូចជាទៅបន្ទន់។ល។ គឺជាគ្រោះថ្នាក់ពេលធ្វើការ។

**<3>ក្នុងករណីធ្វើការងារនៅក្រៅកន្លែងរបស់ក្រុមហ៊ុន**

ចំពោះដំណើរជំនួញ ការធ្វើទីផ្សារ បើគ្មានមូលហេតុពិសេស ដូចជាស្វះស្វែងធ្វើសកម្មភាពឯកជន នឹងត្រូវទទួលស្គាល់ជាគ្រោះថ្នាក់ពេលធ្វើការ។

## ◇ជំងឺដោយសារការងារគឺអ្វី

ក្នុងករណីដែលលក្ខខណ្ឌទាំង 3 ខាងក្រោមត្រូវបានបំពេញ ជាទូទៅគេទទួលស្គាល់ថាជា ជំងឺដោយសារការងារ។

**<1>នៅកន្លែងធ្វើការមានកត្តាបង្កគ្រោះថ្នាក់**

កត្តារូបសាស្ត្របង្កគ្រោះថ្នាក់ សារធាតុគីមី ការងារដែលផ្តល់បន្ទុកដល់រាងកាយធ្ងន់ហួស ។ល។ មានបង្កប់នៅក្នុងការងារ។
(ឧទាហរណ៍) ហ្វីប្រូ (អាសបេស) ។ល។

**<2>នៅកន្លែងដែលមានកត្តាគ្រោះថ្នាក់ខ្លាំង រហូតអាចបង្កជាបញ្ហាសុខភាព**

**<3>របៀបនៃការកើតជាជំងឺ គឺស្របតាមលក្ខណៈវេជ្ជសាស្ត្រ**

ជំងឺដោយសារការងារ គឺកើតឡើងដោយសារអ្នកធ្វើការប៉ះពាល់ជាមួយកត្តាបង្កគ្រោះថ្នាក់នៅក្នុងការងារ ហើយបង្កជាជំងឺ។ ដូច្នេះត្រូវតែជាជំងឺ កើតឡើងក្រោយពីទទួលរងកត្តាបង្កគ្រោះថ្នាក់។ ពេលវេលានៃការកើតជំងឺគឺខុសគ្នាតាមលក្ខណៈ និងលក្ខខណ្ឌនៃការប៉ះពាល់កត្តាបង្កគ្រោះថ្នាក់។

【និយមន័យពាក្យ②】

# គ្រោះថ្នាក់ពេលធ្វើដំណើរទៅធ្វើការ

គ្រោះថ្នាក់ពេលធ្វើដំណើរទៅមកពីធ្វើការ គឺគ្រោះថ្នាក់កើតឡើងដោយសារ ការធ្វើដំណើរទៅមកពីធ្វើការនៃអ្នកធ្វើការ។

## ◇ការធ្វើដំណើរទៅធ្វើការជាអ្វី

គឺការធ្វើដំណើរ①~③ តាមផ្លូវនិងវិធីដែលមានហេតុផលមួយដើម្បីទៅធ្វើការ។

① ការទៅមកចន្លោះកន្លែងស្នាក់នៅនិងកន្លែងធ្វើការ(កន្លែងចាប់ផ្តើម និងបញ្ចប់ការងារ)

② ការធ្វើដំណើរពីកន្លែងធ្វើការ ដែលកំណត់ក្នុងប្រកាសរបស់ក្រសួងសង្គមកិច្ចនិងការងារ ទៅកន្លែងធ្វើការផ្សេងទៀត (ការធ្វើដំណើរពីកន្លែងធ្វើការមួយទៅកន្លែងធ្វើការមួយទៀត)

③ ការធ្វើដំណើរចន្លោះកន្លែងស្នាក់នៅម្នាក់ឯងជិតកន្លែងធ្វើការនិងផ្ទះខ្លួនឯង



## ◇ចន្លោះធ្វើដំណើរទៅធ្វើការ

នៅពេលងាកចេញពីផ្លូវធ្វើដំណើរ ឬផ្អាកការធ្វើដំណើរនោះ ក្នុងចន្លោះងាកចេញ ឬផ្អាកដំណើរនិងការធ្វើដំណើរក្រោយពេលនោះ មិនមែនជាការធ្វើដំណើរទៅធ្វើការទេ។

ប៉ុន្តែ ក្នុងករណីទិញរបស់របរប្រើប្រាស់ឬ ការធ្វើសកម្មភាពស្រដៀងគ្នាក្នុងកំរិតតូចបំផុតនោះ ក្រោយត្រឡប់ចូលផ្លូវដើមវិញ ចាត់ទុកជាការធ្វើដំណើរទៅធ្វើការម្តងទៀត។



## ◇ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃគឺអ្វី

ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ ជាទូទៅគឺមានន័យថាប្រាក់កំរៃមធ្យម។ (ច្បាប់ស្តង់ដារការងារមាត្រាទី12)
ប្រាក់កំរៃមធ្យម ជាទូទៅមានន័យថា ជាទឹកប្រាក់បានមកពីការគណនា ដោយយកទឹកប្រាក់ដែលត្រូវបានបើកអោយអ្នកធ្វើការទាំងអស់ មុនថ្ងៃមានមូលហេតុត្រូវគណនា※ ក្នុងចន្លោះ3ខែ ចែកនឹងចំនួនថ្ងៃ(រាប់ទាំងថ្ងៃមិនធ្វើការ)ក្នុងចន្លោះនោះ។ ប្រាក់កំរៃដែលត្រូវយកមកគណនា ទោះបីជាមានឈ្មោះអ្វីក៏ដោយ គឺទឹកប្រាក់ដែលត្រូវបង់សំរាប់ថ្លៃពលកម្ម ដោយនិយោជក។
ប៉ុន្តែប្រាក់ដែលត្រូវបានបង់មិនប្រចាំ ដូចជាប្រាក់ឧបត្ថម្ភសំរាប់ការរៀបអាពាហ៍ពិពាហ៍ ឬប្រាក់បំណាច់ឆ្នាំដែលត្រូវបានបង់លើសពី 3 ខែម្តងនោះ មិនត្រូវបានរាប់បញ្ចូលសំរាប់ការគណនានោះទេ។
※ជាថ្ងៃដែលគ្រោះថ្នាក់កើតឡើង ធ្វើអោយមានរបួស ឬស្លាប់ ឬជាថ្ងៃដែលគ្រូពេទ្យវិនិច្ឆ័យថាមានជំងឺ ហើយក្នុងករណីដែលថ្ងៃទូទាត់បិទបញ្ជីបើកប្រាក់ខែត្រូវបានកំណត់ នោះគឺថ្ងៃទូទាត់ថ្មីបំផុត។

[ករណីពិសេស]

① ក្នុងករណីដែលប្រាក់កំរៃមធ្យម មិនអាចយកមកប្រើជា ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ បាននោះ វិធីគណនា ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃពិសេសនឹងត្រូវយកមកប្រើ។
  (a) ក្នុងករណីមានការឈប់សម្រាកព្យាបាលរបួសឬជំងឺមិនមានមូលហេតុមកពីការងារ នៅក្នុងចន្លោះពេលដែលយកមកគណនាប្រាក់កំរៃមធ្យម
  (b) ក្នុងករណីអ្នកជំងឺរលាកសួត ត្រូវបានផ្លាស់ប្តូរអោយទៅធ្វើការងារផ្សេង។ល។

② ចំពោះប្រាក់ឧបត្ថម្ភ(សំណង)ឈប់សម្រាក ក្នុងករណី ដែលការព្យាបាលបានកន្លងផុតទៅ 1ឆ្នាំ6ខែ នឹងមានការអនុវត្តន៍ទឹកប្រាក់តិចបំផុតនិងច្រើនបំផុតសំរាប់អាយុនិមួយៗ។ ចំពោះការផ្តល់ប្រាក់សោធន៍និវត្តន៍ នឹងមានការអនុវត្តន៍ទឹកប្រាក់តិចបំផុតនិងច្រើនបំផុតសំរាប់អាយុនិមួយៗ ចាប់តាំងពីខែដំបូងនៃការផ្តល់ប្រាក់សោធន៍និវត្តន៍។

**គំរូនៃការគណនាប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ**

ប្រាក់កំរៃ 20 ម៉ឺនយ៉េនក្នុង១ខែ (ថ្ងៃទូទាត់គឺរាល់ថ្ងៃចុងក្រោយនៃខែ) ហើយគ្រោះថ្នាក់បានកើតឡើងនៅខែ10

20 ម៉ឺនយ៉េន×3 ខែ÷92 ថ្ងៃ[ខែ7(31 ថ្ងៃ) + ខែ 8(31 ថ្ងៃ) + ខែ 9(30 ថ្ងៃ)]
≒6,522 យ៉េន

6,522 យ៉េន×80% ≒ 5,217 យ៉េន
→ ក្នុងការឈប់សម្រាក1ថ្ងៃ ទទួលបាន 80% នៃប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ គឺ 5,217 យ៉េន។

※ «ប្រាក់កំរៃ» មិនរាប់បញ្ចូល ប្រាក់កំរៃម្តងម្កាលដែលត្រូវបានបង់លើសពី 3 ខែម្តងនោះទេ។
ចំពោះប្រាក់បំណាច់ឆ្នាំ ដែលត្រូវបានបង់លើសពី 3 ខែម្តង នឹងត្រូវរាប់បញ្ចូលសំរាប់គណនា «ប្រាក់គណនាមូលដ្ឋានជាថ្ងៃ» នៃប្រាក់សោធន៍និវត្តន៍គ្រួសារពិសេស។ល។

## ◇ប្រាក់គណនាមូលដ្ឋានជាថ្ងៃ ជាអ្វី

ប្រាក់គណនាមូលដ្ឋានជាថ្ងៃ ជាទូទៅ ជាប្រាក់កំរៃពិសេសដែលអ្នកធ្វើការ ទទួលបានពីនិយោជកក្នុងកំឡុងពេល1ឆ្នាំ រាប់ចាប់ពីថ្ងៃដែលគ្រោះថ្នាក់កើតឡើង ដោយសារការធ្វើការ ឬដោយសារការធ្វើដំណើរទៅធ្វើការ ធ្វើអោយមានរបួស ឬស្លាប់ ឬ ថ្ងៃដែលគ្រូពេទ្យវិនិច្ឆ័យថាមានជំងឺ ជាប្រាក់គណនាមូលដ្ឋានជាឆ្នាំ ចែកនឹង 365។

ប្រាក់កំរៃពិសេស ជាប្រាក់កំរៃដូចជាប្រាក់បំណាច់ឆ្នាំ ដែលត្រូវបានបង់លើសពី 3 ខែម្តង ហើយមិនត្រូវបានរាប់ចូលសំរាប់គណនាប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ។ (មិនរាប់ចូលប្រាក់កំរៃ ដូចជាប្រាក់ឧបត្ថម្ភសំរាប់ការរៀបអាពាហ៍ពិពាហ៍។ល។)

ប៉ុន្តែ ក្នុងករណីដែល ប្រាក់កំរៃពិសេសសរុប លើសពី 20% នៃ ប្រាក់ឧបត្ថម្ភមូលដ្ឋានជាឆ្នាំ (ស្មើនឹង ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ 365 ថ្ងៃ) នោះទឹកប្រាក់ 20%នៃ ប្រាក់ឧបត្ថម្ភមូលដ្ឋានជាឆ្នាំ នឹងក្លាយជា គណនាមូលដ្ឋានជាឆ្នាំ។ (ចំនួនច្រើនបំផុតគឺ 150 ម៉ឺនយ៉េន)

【លក្ខខណ្ឌទទួលស្គាល់តាមប្រភេទជំងឺ① 】

# ជំងឺខួរក្បាល បេះដូង

«ជំងឺសរសៃឈាមខួរក្បាល» ដូចជាជំងឺងាប់ជាលិកាខួរក្បាល «ជំងឺបេះដូង» ដូចជាគាំងបេះដូង ជាជំងឺសរសៃឈាម ដែលកើតឡើងដោយសារកត្តារស់នៅប្រចាំថ្ងៃ ដូចជា អាយុកើនឡើង ចំណីអាហារ បរិស្ថានរស់នៅ ឬកត្តាហ្សែន ហើយចេញជាអាការអាក្រក់បន្តិចម្តងៗ ប៉ុន្តែក៏មានករណីខ្លះបណ្តាលមកពីការធ្វើការដែរ។

ជំងឺខួរក្បាលឬបេះដូង «ដែលបណ្តាលយ៉ាងច្បាស់មកពីបន្ទុកធ្ងន់ហួសកំរិតនៃការងារ※» ជាកម្មវត្ថុអាចទទួលប្រាក់សំណងបាន។

※បន្ទុកធ្ងន់ហួសកំរិត គឺជាបន្ទុកដែលត្រូវបានទទួលស្គាល់ជាសត្យានុម័ត តាមរយៈបទពិសោធន៍វេជ្ជសាស្ត្រ ថាបានធ្វើអោយជំងឺសរសៃឈាមដែលបង្កើតជាជំងឺខួរក្បាលឬបេះដូង ធ្ងន់ឡើងលឿនជាងការវិវឌ្ឍន៍តាមធម្មជាតិ។

<ជំងឺជាកម្មវត្ថុ>

**○ជំងឺសរសៃឈាមខួរក្បាល**

- ជំងឺចេញឈាមក្នុងខួរក្បាល (ឈាមក្នុងខួរក្បាល)
- ជំងឺហូរឈាមក្នុងស្រោមខួរក្បាល
- ជំងឺងាប់ជាលិកាខួរក្បាល
- រោគខួរក្បាលបណ្តាលមកពីលើសឈាម

**○ជំងឺបេះដូងបណ្តាលមកពីកង្វះឈាម។ល។**

- ជំងឺងាប់ជាលិកាបេះដូង
- ជំងឺខ្វះឈាមទៅចិញ្ចឹមបេះដូង
- ជំងឺគាំងបេះដូង(រួមទាំងការស្លាប់បន្ទាន់ដោយសារបេះដូង)
- ជំងឺប៉ោងសរសៃឈាមក្រហម

## [លក្ខខណ្ឌទទួលស្គាល់ជាគ្រោះថ្នាក់ការងារ]

ករណីណាមួយក្នុងចំណោមខាងក្រោម ត្រូវបានទទួលស្គាល់ជាគ្រោះថ្នាក់ការងារ។

### 1. ព្រឹត្តិការណ៍មិនធម្មតា

បានជួបព្រឹត្តិការណ៍មិនធម្មតា ដែលសភាពនៃការកើតឡើង អាចបង្ហាញយ៉ាងច្បាស់ពីពេលវេលានិងទីកន្លែង ក្នុងចន្លោះពេលមុនកើតជំងឺដល់មួយថ្ងៃមុន

អាចមានដូចជាករណី ពាក់ព័ន្ធដោយផ្ទាល់នឹងគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស ពេលធ្វើការ ហើយទទួលបន្ទុកផ្នែកអារម្មណ៍ធ្ងន់ ឬក្នុងពេលមានគ្រោះថ្នាក់បានពាក់ព័ន្ធក្នុងការងារជួយសង្គ្រោះឬដោះស្រាយបញ្ហាគ្រោះថ្នាក់ ហើយទទួលបន្ទុកផ្នែករាងកាយធ្ងន់ធ្ងរ។

### 2. ការងារធ្ងន់ហួសកំរិតក្នុងរយៈពេលខ្លី

បានធ្វើការធ្ងន់ហួសកំរិតថ្មីៗមុនកើតជំងឺ

(1)ក្នុងករណីបានធ្វើការធ្ងន់ហួសកំរិត ក្នុងចន្លោះពេលមុនកើតជំងឺដល់មួយថ្ងៃមុន (2)ទោះក្នុងករណី ក្នុងចន្លោះពេលមុនកើតជំងឺដល់មួយថ្ងៃមុន មិនត្រូវបានទទួលស្គាល់ថាបានធ្វើការធ្ងន់ហួសកំរិត ក្នុងករណីបានធ្វើការធ្ងន់ហួសកំរិតជាប់ៗគ្នា ក្នុងកំឡុងពេល1សប្តាហ៍មុននោះ គេគិតថា ការងារនិងការកើតជំងឺគឺមានទំនាក់ទំនងគ្នា។

### 3. ការងារធ្ងន់ហួសកំរិតក្នុងរយៈពេលវែង

មុនពេលកើតជំងឺ បានធ្វើការធ្ងន់ហួសកំរិតក្នុងរយៈពេលវែង ដែលធ្វើអោយការនឿយហត់គរឡើង

នៅពេលដែលការថែមម៉ោងលើសពី 45 ម៉ោង អូសបន្លាយកាន់តែវែង ទំនាក់ទំនងកាន់តែខ្លាំង ហើយក្នុងករណីដែលមានការថែមម៉ោងលើសពី 100 ម៉ោងក្នុង1ខែមុនកើតជំងឺ ឬក្នុងករណីដែលការថែមម៉ោងលើសពី 80 ម៉ោងជាមធ្យមក្នុងកំឡុងពេល 2~6ខែនោះ គេវាយតំលៃថាការងារនិងការកើតជំងឺគឺមានទំនាក់ទំនងគ្នាខ្លាំង។

※ចំពោះ 2 និង 3 ក្រៅពីចំនួនម៉ោងធ្វើការ ទម្រង់ពេលវេលាធ្វើការ(ធ្វើការមិនទៀងទាត់ ធ្វើការរយៈពេលវែង ការងារធ្វើដំណើរច្រើន ការងារប្តូរផ្លាស់គ្នា ការងារពេលអាធ្រាត) បរិស្ថានកន្លែងធ្វើការ (សំណើម សំឡេង គំលាតម៉ោង) ការតឹងតែងផ្នែកអារម្មណ៍។ល។ ក៏កំពុងត្រូវបានរាប់បញ្ចូលជាកត្តាបន្ទុកការងារដែរ។

【លក្ខខណ្ឌទទួលស្គាល់តាមប្រភេទជំងឺ② 】

# ជំងឺសតិអារម្មណ៍

គេគិតថាជំងឺសតិអារម្មណ៍កើតឡើងដោយទំនាក់ទំនងរវាងទំហំបន្ទុកផ្លូវចិត្តពីខាងក្រៅ(ស្ត្រេស) និងសម្ថភាពទ្រទ្រង់របស់មនុស្សម្នាក់ៗ។
ក្នុងករណីដែលជំងឺសតិអារម្មណ៍កើតឡើងដោយបន្ទុកផ្លូវចិត្ត※ ដោយសារការងារនោះ ជាកម្មវត្ថុនៃសំណងគ្រោះថ្នាក់ការងារ។

※បន្ទុកផ្លូវចិត្តដោយសារការងារ គឺជាបន្ទុកផ្លូវចិត្ត ដែលអាចបង្កជាជំងឺពាក់ព័ន្ធជាយថាហេតុ។

**[លក្ខខណ្ឌទទួលស្គាល់ជាគ្រោះថ្នាក់ការងារ]**

ក្នុងករណីលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានបំពេញ នឹងត្រូវបានទទួលស្គាល់ជាគ្រោះថ្នាក់ការងារ។

## 1. កើតជំងឺសតិអារម្មណ៍ ក្នុងកំរិតទទួលស្គាល់កំណត់មួយ

ជាជំងឺសតិអារម្មណ៍ ដែលមានចែងក្នុងបំណែងចែកជំងឺអន្តរជាតិកំណែទី10(ICD-10) ជំពូកទីV «ជំងឺសតិអារម្មណ៍និងសកម្មភាព»។ (មិនរាប់បញ្ចូលជំងឺវង្វេងនិងរបួសក្បាលផ្នែកខាងក្រៅទេ)

(ឧទាហរណ៍) ជំងឺមិនស្រួលអារម្មណ៍ ជំងឺស្ត្រេសបន្ទាន់

## 2. ត្រូវបានទទួលស្គាល់ថា មានបន្ទុកផ្លូវចិត្តដោយសារការងារខ្លាំង ក្នុងកំឡុង6ខែមុនកើតជំងឺសតិអារម្មណ៍

(ឧទាហរណ៍) មានការផ្តាញ់ផ្តាល ធ្វើបាប វាយដំ ខ្លាំង ឬមានព្រឹត្តិការណ៍ធ្វើអោយខ្លឹមសារការងារ បរិមាណការងារប្រែប្រួលខ្លាំង។ល។

※ចំពោះករណីដែលព្រឹត្តិការណ៍ដូចជា ការធ្វើបាប ការរំខានផ្លូវភេទកើតឡើងម្តងហើយម្តងទៀត បើសិនជាចាប់ផ្តើមមុនកើតជាជំងឺ 6 ខែ ហើយបន្តរហូតនោះ គេនឹងធ្វើការវាយតំលៃលើទំហំបន្ទុកផ្លូវចិត្តនៅចំណុចចាប់ផ្តើមកើតឡើង។

## 3. មិនត្រូវបានទទួលស្គាល់ថា មានជំងឺសតិអារម្មណ៍ដោយបន្ទុកផ្លូវចិត្តរឿងឯកជន ក្រៅពីការងារ

គេនឹងធ្វើការវិនិច្ឆ័យយ៉ាងដិតដល់ ថាជំងឺមិនមែនកើតឡើងដោយ ព្រឹត្តិការណ៍ឯកជនរបស់ខ្លួន (លែងលះ រស់នៅបែកគ្នាជាមួយប្តីប្រពន្ធ។ល។) ឬព្រឹត្តិការណ៍ឯកជនរបស់គ្រួសារ (ការស្លាប់របស់ប្តីប្រពន្ធ កូន ឪពុកម្តាយ បងប្អូន។ល។) នោះទេ។
គេនឹងធ្វើការវិនិច្ឆ័យយ៉ាងដិតដល់ ថាមិនមែនជាការរើឡើងវិញនៃជំងឺសតិអារម្មណ៍ ពិនិត្យមើលថាមានកត្តាផ្ទាល់ខ្លួនដែរឬអត់ ក្នុងករណីដែលមានកត្តាផ្ទាល់ខ្លួន ថាតើវាជាមូលហេតុនៃការកើតជំងឺដែរឬទេ។

【លក្ខខណ្ឌទទួលស្គាល់តាមប្រភេទជំងឺ③ 】

# ភាពមិនប្រក្រតីនៃអវៈយវៈខាងលើ

នៅពេលប្រើដើមដៃឬប្រអប់ដៃច្រើនហួសពេក នៅពេលខ្លះមានការរលាក ពីក មកស្មា ដើមដៃ ប្រអប់ដៃ ម្រាមដៃ ឬ ភាពមិនប្រក្រតី នៅសន្លាក់ សរសៃរពួរ។ល។
ភាពមិនប្រក្រតីនៃអវៈយវៈខាងលើ គឺសភាពរលាក ឬភាពមិនប្រក្រតីលើរបស់ទាំងអស់នេះ។

<រោគវិនិច្ឆ័យសំខាន់ៗ>

- ជំងឺរលាកខាងក្រៅ(ក្នុង)ឆ្អឹងដើមដៃ
- អាការសរសៃកំភួនដៃ
- ជំងឺសាច់ដុំសំរាប់ផ្ការដៃទៅក្រៅ(ក្នុង)
- រលាកសន្លាក់ដៃ
- រលាកស្រោមព័ន្ធសាច់ដុំ
- រោគសរសៃប្រអប់ដៃ
- ជំងឺញ័រដៃសរសេរមិនបាន

**[លក្ខខណ្ឌទទួលស្គាល់ជាគ្រោះថ្នាក់ការងារ]**

ក្នុងករណីលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានបំពេញ នឹងត្រូវបានទទួលស្គាល់ជាគ្រោះថ្នាក់ការងារ។

## 1. បន្ទាប់ពីធ្វើការដែលមានបន្ទុកខ្លាំងដល់អវៈយវៈខាងលើ※ ។ល។ ក្នុងកំឡុងពេលមួយ(ជាទូទៅលើសពី6ខែ)

សំខាន់មានដូចជាប្រភេទការងារខាងក្រោម។

① ការងារត្រូវធ្វើចលនាអវៈយវៈខាងលើទៅមកៗច្រើន
② ការងារធ្វើក្នុងសភាពលើកអវៈយវៈខាងលើ
③ ការងារដែលធ្វើចលនាកនិងស្មាតិច ហើយទម្រង់ខ្លួនមិនប្រែប្រួល
④ធ្វើការងារដែលដាក់បន្ទុកទៅលើតំបន់កំណត់មួយនៃអវៈយវៈខាងលើ

※អវៈយវៈខាងលើមាន ផ្នែកខាងក្រោយនៃក្បាល ក ស្មា ដើមដៃ កំភួនដៃ កដៃ ម្រាមដៃ។

## 2.បានធ្វើការធ្ងន់ហួសកំរិតមុនកើតជំងឺ

ក្នុងកំឡុងពេល 3 ខែមុនកើតជំងឺ បានធ្វើការដែលមានបន្ទុកខ្លាំងដល់អវៈយវៈខាងលើ ក្នុងស្ថានភាពដូចខាងក្រោម។

- ក្នុងករណីដែលបរិមាណការងារស្ទើរតែមិនប្រែប្រួល
  បានធ្វើការច្រើនជាង អ្នកធ្វើការស្រដៀងគ្នា ដែលមានភេទដូចគ្នា និងអាយុប្រហែលគ្នា លើសពី10% រយៈពេល3ខែ
- ក្នុងករណីដែលបរិមាណការងារមានការប្រែប្រួល
  ① ថ្ងៃដែលបរិមាណការងារក្នុង1ថ្ងៃលើសថ្ងៃធម្មតា លើសពី20% មាន10ថ្ងៃក្នុង1ខែ ហើយបន្តរយៈពេល 3 ខែ (ទោះបីបរិមាណការងារទាំងមូលក្នុង1ខែដូចប្រក្រតីក៏ដោយ)
  ② ថ្ងៃដែលបរិមាណការងារក្នុងកំឡុងពេល1ភាគ3នៃការងារ1ថ្ងៃ លើសធម្មតាលើសពី20% មាន10ថ្ងៃក្នុង1ខែ ហើយបន្តរយៈពេល 3 ខែ (ទោះការងារមធ្យមក្នុង 1ថ្ងៃដូចប្រក្រតីក៏ដោយ)

※ពេលវិនិច្ឆ័យថាបានធ្វើការហួសកំរិតឬអត់ ក្រៅពីបរិមាណការងារ ស្ថានភាពខាងក្រោមក៏ត្រូវបានយកមកពិចារណាដែរ។

- ការងាររយៈពេលវែង ការងារបន្តជាប់ ・មានការបារម្ភខ្លាំង ・ការងារទទួលបញ្ជាពីអ្នកដទៃ ហើយមានចង្វាក់ញាប់ខ្លាំង
- បរិស្ថានការងារមិនសមស្រប ・ត្រូវការបញ្ចេញកំលាំងខ្លាំងហួសកំរិត

## 3. ត្រូវបានទទួលស្គាល់បែបវេជ្ជសាស្ត្រ ថាការងារធ្ងន់ហួសកំរិត និងការកើតជាជំងឺមានទំនាក់ទំនងគ្នា

【លក្ខខណ្ឌទទួលស្គាល់តាមប្រភេទជំងឺ④ 】

# ជំងឺឈឺចង្កេះ

ជំងឺឈឺចង្កេះដែលអាចទទួលសំណងគ្រោះថ្នាក់ការងារ មាន2ប្រភេទដូចខាងក្រោម ដែលត្រូវធ្វើការព្យាបាល ហើយប្រភេទនិមួយៗមាន លក្ខខណ្ឌទទួលស្គាល់គ្រោះថ្នាក់ការងារ។

**[លក្ខខណ្ឌទទួលស្គាល់ជាគ្រោះថ្នាក់ការងារ]**

## 1. ជំងឺឈឺចង្កេះដែលមានមូលហេតុលក្ខណៈគ្រោះថ្នាក់

ជាការឈឺចង្កេះដោយសាររបួស។ល។ ហើយបំពេញលក្ខខណ្ឌ①និង②ខាងក្រោម

① អាចបញ្ជាក់បានយ៉ាងច្បាស់ថា របួសចង្កេះ ឬបានរងកំលាំងខ្លាំងដែលជាមូលហេតុនាំអោយមានរបួសចង្កេះ គឺដោយសារព្រឹត្តិការណ៍ផ្សេងៗដែលកើតឡើងនៅពេលកំពុងធ្វើការ។

② អាចបញ្ជាក់តាមបែបជីវសាស្ត្រថា កំលាំងដែលធ្វើអំពើលើចង្កេះ បានធ្វើអោយកើតជំងឺឈឺចង្កេះ ឬធ្វើអោយអ្នកដែលមានប្រវត្តិកើតជំងឺឈឺចង្កេះ រើឡើងវិញ។

## 2. ជំងឺឈឺចង្កេះដែលគ្មានមូលហេតុលក្ខណៈគ្រោះថ្នាក់

ជំងឺឈឺចង្កេះដែលគ្មានមូលហេតុលក្ខណៈគ្រោះថ្នាក់ ត្រូវបានគេបែងចែកសំរាប់វិនិច្ឆ័យជា2ប្រភេទដូចខាងក្រោម។

### ◇ជំងឺឈឺចង្កេះដែលកើតឡើងដោយសារភាពហត់នឿយនៃសាច់ដុំ។ល។

ជំងឺឈឺចង្កេះដែលមានមូលហេតុមកពីភាពនឿយហត់នៃសាច់ដុំ។ល។ ដោយសារធ្វើការងារដូចខាងក្រោមក្នុងរយៈពេលខ្លី(ប្រហែលលើសពី 3 ខែ) អាចទទួលបានសំណងគ្រោះថ្នាក់ការងារ។

- ការងារដែលត្រូវលើករបស់ដែលមានទំងន់លើសពី20kg ឬការងារដែលត្រូវលើករបស់ទំងន់ផ្សេងៗគ្នាក្នុងស្ថានភាពអោន
- ការងារដែលត្រូវរក្សាទម្រង់ខ្លួន ដែលមិនធម្មជាតិខ្លាំងចំពោះចង្កេះ រយៈពេលរាប់ម៉ោងរៀងរាល់ថ្ងៃ
- ការងារដែលត្រូវរក្សាទម្រង់ខ្លួននៅទ្រឹង ហើយមិនអាចងើបឈរក្នុងរយៈពេលវែង
- ការងារដែលត្រូវបន្តធ្វើការងារដែលធ្វើអោយចង្កេះមានរំញ័រខ្លាំង

### ◇ជំងឺឈឺចង្កេះដែលបណ្តាលមកពីការប្រែប្រួលនៃឆ្អឹង

ជំងឺឈឺចង្កេះដែលមានមូលហេតុមកពីការប្រែប្រួលនៃឆ្អឹង ដោយសារធ្វើការងារជាមួយរបស់ធ្ងន់ដូចខាងក្រោមក្នុងរយៈពេលវែង (ប្រហែលលើសពី 10 ឆ្នាំ) អាចទទួលបានសំណងគ្រោះថ្នាក់ការងារបាន។

- ការងារដែលត្រូវលើករបស់ទំងន់លើសពី 30kg ក្នុងកំឡុងពេលលើសពី 1ភាគ3 នៃម៉ោងធ្វើការ
- ការងារដែលត្រូវលើករបស់ទំងន់លើសពី 20kg ក្នុងកំឡុងពេលលើសពី ពាក់កណ្តាលនៃម៉ោងធ្វើការ

※ជំងឺឈឺចង្កេះដែលបណ្តាលមកពីការប្រែប្រួលនៃឆ្អឹង អាចទទួលបានសំណងគ្រោះថ្នាក់ការងារ លុះត្រាតែការប្រែប្រួលនោះ«លើសពីកំរិត នៃការប្រែប្រួលឆ្អឹងដោយសារអាយុខ្លាំង»។